# រួមបញ្ចូលទឹកនៅក្នុងឧបករណ៍អាសន្នរបស់អ្នក។







ទឹកមួយហ្គាឡុង សម្រាប់មួយនាក់ មួយថ្ងៃ រយៈពេល ១៤ ថ្ងៃ

regionalh2o.org/emergency-preparedness

# ការផ្គត់ផ្គង់ទឹក សម្រាប់ពេលអាសន្ន គឺអាចធ្វើបានដោយស្រួល។

ទឹកដែលផ្គត់ផ្គង់សម្រាប់ពេលអាសន្ន គឺដូចជាទឹកដបដែលអ្នកអាច ទិញ ឬទឹកអ្នកអាចបំពេញក្នុងធុង (ឬដប ឬអ្វីផ្សេងៗ) ដោយខ្លួនរបស់អ្នក។ ប្រសិនបើអ្នកទិញទឹកដបអ្នកត្រូវ ចាំប្រាកដថាទុកនៅក្នុងធុង (ឬដប)ដើមរបស់វា ហើយកុំបើកវារហូតទាល់តែអ្នកត្រូវការប្រើប្រាស់។

ប្រសិនបើអ្នកប្រើធុងរបស់អ្នក អ្នកត្រូវ ដឹងប្រាកដថាធុងនោះគ្មានកន្លែងណាដែលទឹកអាចលេចចេញបាន ហើយធុងនោះ ធ្វើពីផ្លាស្ទិក ឬ ដែកដែលបានធ្វើសម្រាប់ដាក់ឬផ្គត់ផ្គង់ទឹក ហើយធុងនោះ អ្នកបានសម្អាត (ឬអ្នកណាផ្សេងបានសម្អាត) យ៉ាងត្រឹមត្រូវ មុនពេលអ្នក ដាក់ទឹកម៉ាស៊ីននៅក្នុងវា។

## របៀបសម្អាតធុង:

១ ពេលលាងធុង ប្រើសាប៊ូលាងចាន និងទឹកស្អាត ដើម្បីលាងសម្អាតធុង និង គម្របរបស់វាឱ្យបានហ្មត់ចត់។

២ លាងជម្រះធុងរបស់អ្នកឱ្យបានល្អ ដោយប្រើទឹកស្អាត ហើយចាក់ទឹកនោះចោល។

៣ លាយធាតុ chlorine bleach ដែលគ្មានក្លិន ចំនួនមួយស្លាបព្រាតែ ជាមួយទឹកចំនួនបួនពែង។

៤ ចាក់ទឹកដែលបានលាយជាមួយ bleach ទៅក្នុងធុង រួចបិទគម្រប ហើយមួលបន្តឹង។

៥ គ្រលុកធុងឱ្យខ្លាំងក្លា រយៈពេល ៣០ វិនាទី ហើយពិនិត្យមើលឱ្យប្រាកដថាផ្ទៃធុងទាំងអស់បានសើមសព្វ។

៦ ចាក់ទឹក bleach ចេញហើយទុកឱ្យធុងទទេរបស់អ្នកស្ងួត។

## ការបំពេញទឹកទៅក្នុងធុងរបស់អ្នក(ធុងដែលបានលាងស្អាតហើយ):

១ ចាក់ទឹកទៅក្នុងធុងរបស់អ្នកឱ្យពេញដល់មាត់ - ប្រយ័ត្ន កុំឱ្យដៃ ឬក្បាលទឹក ឬអ្វីផ្សេងទៀតប៉ះមាត់ធុង - នេះដើម្បីការពារកុំឱ្យរបស់កខ្វក់ចូលទៅទឹក។

២ ជំហាននេះ ខុសគ្នាបន្តិច អាស្រ័យ លើទីកន្លែងណាដែលអ្នកបានទឹកមក។

**ទឹកបានពីអណ្តូង ឬកប្រភពណាមិនស្អាត:** → អ្នកនឹងត្រូវដាក់ bleach ចំនួន ១/៨ ស្លាបព្រាតែ លាយជាមួយទឹកមួយហ្គាឡុង។

ចំពោះទឹកដែលសេវាណាមួយផ្តល់អោយ ដូចពីទីក្រុងរបស់អ្នក អ្នកមិនត្រូវការសម្អាតទឹកនោះទេព្រោះទឹកនោះស្អាតរួចហើយ។

៣ ដាក់គម្របទៅក្បាលធុងវិញ។ នៅពេលអ្នកដាក់គម្រប ទៅលើមាត់ធុងនោះ សូមប្រយ័ត្ន កុំឱ្យប៉ះគម្របនៅខាងក្រោម ឬខាងក្នុង ហើយត្រូវដឹងទៅទៀតប្រាកដថាគម្របត្រូវមាត់ធុងល្មម មិនធូរឬតឹងពេក។

៤ ដាក់ថ្ងៃ ខែ ឆ្នាំ លើធុងទឹករបស់អ្នក ដូច្នេះអ្នកដឹងថា អ្នកបានដាក់ទឹកក្នុងធុងពីកាលណា។

## អ្វីដែលអ្នក ត្រូវតែធ្វើឬមិនគួរធ្វើពេលផ្គត់ផ្គង់ទឹក:

**ត្រូវធ្វើ** - ទិញទឹកដបពីហាង ឬប្រើធុងផ្ទាល់ខ្លួនរបស់អ្នក ដើម្បីផ្គត់ផ្គង់ទឹក។

**ត្រូវធ្វើ** - ប្រើធុងដែលបានធ្វើសម្រាប់ដាក់អាហារឬទឹកផឹក ដូចជាធុងប្រើប្រាសក្នុងពេល camping ឬនៅពេលដើលេងកម្សាន្តឆ្ងាយទីក្រុង (outdoor activities) ។

**កុំធ្វើ** - កុំប្រើធុងឬដបណាធ្វើពីធាតុកែវ ឬធុង ឬដបណាដែលបានប្រើដាក់ទឹកដោះគោឬទឹកផ្លែឈើ ឬសារធាតុគីមី។

**ត្រូវធ្វើ** - អ្នកគួរផ្លាស់ប្តូរទឹកដែលបានផ្គត់ផ្គង់រៀងរាល់រយៈប្រាំមួយខែម្តង (ទឹកនោះមិនខ្លាយទៅជាខូចទេ ដូច្នេះ ប្រសិនបើអ្នកត្រូវការ ប្រើវាក្នុងគ្រាអាសន្ន ហើយវាចាស់ជាងប្រាំមួយខែទៅហើយ អ្នកប្រើទៅចោះ)។

**ត្រូវធ្វើ** - ផ្គត់ផ្គង់ទឹកឱ្យច្រើនតាមដែលអ្នកអាចធ្វើបាន (ប្រសិនបើចង់ធ្វើបន្តិចម្តងៗ៖ អ្នកផ្តើមការផ្គត់ផ្គង់បន្តិចម្តងៗ ហើយថែមតរទៅ។)

**ត្រូវធ្វើ** - រក្សាទុកទឹករបស់អ្នក នៅកន្លែងត្រជាក់ និងងងឹត (ប្រសិនបើអាច ធ្វើបាន)។

សមាគម Regional Water Providers Consortium ផ្តល់ការដឹកនាំក្នុងផែនការ ការគ្រប់គ្រង និងភាពធន់នៃទឹកផឹក នៅតំបន់ទីប្រជុំជន Portland, Oregon។

អ្នកអាចទទួលបានព័ត៌មានបន្ថែម ហើយនិងធនធាននៅ៖ **www.regionalh2o.org**។

KHMER

PRINTED ON RECYCLED PAPER

© REGIONAL WATER PROVIDERS CONSORTIUM 2022

REGIONAL WATER PROVIDERS CONSORTIUM